ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ**
**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ**
លេខ: ១៣៤២ សហអ

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

តាមរយៈ : ឯកឧត្តមអគ្គនាយកពាណិជ្ជកម្មអន្តរជាតិ និង ឯកឧត្តមរដ្ឋលេខាធិការ

កម្មវត្ថុ : របាយការណ៍ស្តីពី កិច្ចប្រជុំគណៈកម្មការអនុវត្តន៍គម្រោង (IC) លើកទី២១

ភ្ជាប់ជូន : បញ្ជីវត្តមាន របៀបវារៈនៃកិច្ចប្រជុំ បទបង្ហាញ កំណត់ហេតុ និងបញ្ជីអនុម័ត

ឆ្នាំពីរពាន់ដប់ពីរ ខែកក្កដា ថ្ងៃទីដប់ នៅក្រសួងពាណិជ្ជកម្ម បានបើកកិច្ចប្រជុំនៃគណៈកម្មការអនុវត្តន៍គម្រោង (IC) លើកទី២១ ក្រោមអធិបតីភាព ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និង ជាប្រធានគណៈកម្មការអនុវត្តន៍ (IC) ដោយមានសមាជិក-សមាជិកា មកពីក្រសួងស្ថាប័នដែលពាក់ព័ន្ធ ចូលរួមដូចមានក្នុងបញ្ជីវត្តមានជាឧបសម្ព័ន្ធ១។

របៀបវារៈកិច្ចប្រជុំ (ឧបសម្ព័ន្ធ២) និងចំណុចសំខាន់ៗ ដែលបានពិភាក្សារួមមាន:

- របាយការណ៍វឌ្ឍនភាពរបស់គម្រោង TDSP, EIF
- របាយការណ៍ត្រួតពិនិត្យលទ្ធផលគម្រោងបានបញ្ចប់ (Top Ten Products, Export Training- SME Training) និងគម្រោង Value Chain Information Unit របស់នាយកដ្ឋានជំរុញពាណិជ្ជកម្ម
- ការពិភាក្សា-អនុម័តគម្រោងយុទ្ធសាស្ត្រថ្មីស្តីអំពី Support of ASYCUDA World System របស់អគ្គនាយកដ្ឋានគយ-រដ្ឋាករ

ឯកឧត្តម ប៉ាន សូរស័ក្តិ បានជូនដំណឹងអំពីការសុំឈប់សម្រាកការងារមិនយកបៀវត្សរយៈពេលមួយឆ្នាំរបស់ លោក ឈៀង ពេជ្រ ចាប់ពី ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ តទៅ និងជំនួសដោយ លោក ស៊ឹម សុខខេង បច្ចុប្បន្នជាអនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា មកទទួលបន្ថែម ជាប្រធានស្តីទីនាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ។ បន្ទាប់ពីលោកស្រី ម៉ម ម៉ានី ជំនួសប្រធានស្តីទី នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបានរាយការណ៍អំពីវឌ្ឍនភាពរបស់គម្រោង TDSP តាមរយៈ បទបង្ហាញ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ៣ រួចមក និង អមដោយបទបង្ហាញបំពេញបន្ថែម របស់សហសេវិក នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ អំពី វឌ្ឍនភាពរបស់គម្រោង EIF របាយការណ៍ត្រួតពិនិត្យលទ្ធផលគម្រោងបានបញ្ចប់ ពីគម្រោង Top Ten Products, គម្រោង Export Training-SME Training និង គម្រោងសុំបន្ត Value Chain Information Unit របស់នាយកដ្ឋានជំរុញពាណិជ្ជកម្ម ដែលបានធ្វើតាមស្មារតីណែនាំ របស់កិច្ចប្រជុំគណៈកម្មាការអនុវត្តន៍គម្រោងលើកទី២០។ ការបញ្ជាក់ចំណុចសំខាន់ៗ របស់មន្ត្រីអគ្គនាយកដ្ឋានគយ-រដ្ឋាករ ជូនអង្គប្រជុំបានពិភាក្សាយ៉ាងលម្អិត និងការពិភាក្សាគម្រោងយុទ្ធសាស្ត្រថ្មីស្តីអំពី ASYCUDA World System អគ្គនាយកដ្ឋានគយ-រដ្ឋាករដែលកំណត់ហេតុពិស្តារមានភ្ជាប់ជាឧបសម្ព័ន្ធ៤។ ជូសមុខគណៈកម្មាការអនុវត្តន៍គម្រោង ឯកឧត្តម ប៉ាន សូរស័ក្តិ បានធ្វើការបូកសរុបជាលទ្ធផលរួម និងផ្តល់អនុសាសន៍ដូចខាងក្រោម:

- គណៈកម្មាការអនុវត្តន៍គម្រោង (IC) បានណែនាំលេខាធិការដ្ឋាន DICO ជាថ្មីម្តងទៀត អោយរកពេលសមស្របមួយរៀបចំកិច្ចប្រជុំក្រុមការងាររបស់សរសរស្តម្ភទាំងបី អំពីទឹកប្រាក់នៅសល់ចំនួន 1,168.398.50 USD ក្រោមការដឹកនាំរបស់ ឯកឧត្តម សុខ សុភ័ក្ត្រ ជាអ្នកដឹកនាំកិច្ច

ប្រជុំផ្ទាល់ដើម្បីជម្រាបជូន-ពិភាក្សា និងសម្រេចលើការសម្រាំងយកគម្រោងយុទ្ធសាស្ត្រអនុវត្ត សម្រាប់សសរស្តម្ភនីមួយៗ របស់ខ្លួន។

- ដោយយោងតាមការធ្វើបទបង្ហាញអំពីរបាយការណ៍ត្រួតពិនិត្យលទ្ធផល M&E របស់លេខាធិការដ្ឋាន DICO ឃើញថាគម្រោងនេះមិនអាចសម្រេចបានលទ្ធផលរំពឹងទុក មូលហេតុដោយការចាត់តាំងក្រុមការងារយឺតយ៉ាវ ការជ្រើសរើសទីប្រឹក្សាជាតិ មិនស៊ីសង្វាក់ជាមួយទីក្សាអន្តរជាតិ ការខ្វះខាតថវិកាឧបត្ថមបណ្តាលឱ្យសមាជិក Value Chain Information Unit ធ្វើការមិនជិតដល់ កង្វះខាតពត៌មានសម្រាប់ស្រាវជ្រាវជាដើម។ ផ្អែកលើបញ្ហានេះអង្គប្រជុំយល់ព្រមឱ្យនាយកដ្ឋានជំរុញពាណិជ្ជកម្ម លេខាធិការដ្ឋានDICO និងស្ថាប័នពាក់ព័ន្ធនានាធ្វើការរួមគ្នាកែសម្រួលគម្រោង Value Chain Information Unit ទាំងមូល ដោយតម្រូវឱ្យមានជាជម្រើសសមស្រប ដាក់ជូនគណៈកម្មាការអនុវត្តន៍គម្រោង នៅកិច្ចប្រជុំពេលខាងមុខ ។
- អនុម័តអំពីគម្រោងយុទ្ធសាស្ត្រថ្មី ASYCUDA World System របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ដោយមានទឹកប្រាក់ 1,129,153.50 USD ដូចមានក្នុងបញ្ជីអនុម័តភ្ជាប់ជាឧបសម្ព័ន្ធ៥។ ដោយសារតែគម្រោងនេះត្រូវសុំការសម្រេចពី SSC មុនថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១២ និងដោយហេតុថា កិច្ចសន្យាមួយចំនួនត្រូវបន្តមុនកាលបរិច្ឆេទនោះ ដូច្នេះអង្គប្រជុំបានជូនភារកិច្ចជូន ឯកឧត្តម ប៉ាន សូរស័ក្តិ ដើម្បីផ្តល់ឯកសារតាមអ៊ីមែល ជូនសមាជិក SSC និងឯកឧត្តមទេសរដ្ឋមន្ត្រីក្នុងនាមជាប្រធាន SSC ដើម្បីសុំការសម្រេច។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១៧:០០ ក្នុងបរិយាកាសរីករាយ និងប្រកបដោយលទ្ធផលល្អ។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម មេត្តាជ្រាបជារបាយការណ៍ ។

សូម ឯកឧត្តម ទេសរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី 11 ខែ កក្កដា ឆ្នាំ២០១២

អ្នកធ្វើរបាយការណ៍

ហង់ សុជីវិន

លេខាធិការ

ចម្លងជូន:

- ឯ.ឧ ប្រធាន - អនុប្រធាន និងសមាជិកគណៈកម្មការអនុវត្តគម្រោង
- ឯ.ឧ លោក - លោកស្រី ប្រធានក្រុមការងារសសរស្តម្ភទី១ ទី២ និងទី៣

គោរពជូន **ឯកឧត្តមរដ្ឋលេខាធិការ**

ដើម្បីសុំការឯកភាពគោរពបញ្ជូនជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ជ្រាប

11 កក្កដា 2012

**សុខ សុភ័ក្រ្ត**

សមាជិកអចិន្ត្រៃយ៍ គណៈកម្មាការអនុវត្តគម្រោង

បានឃើញ និង ឯកភាព

គោរពបញ្ជូនជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី**

**ប៉ាន សូរស័ក្តិ**

ប្រធានគណៈកម្មាការអនុវត្តគម្រោង